# CCHR៖ ជនជាប់ចោទខ្លះរងការឃុំខ្លួននិងកាត់ទោសដោយគ្មានមេធាវី

**ដោយ សុខ សេរី**

**2011-03-06**

ការសិក្សាស្រាវជ្រាវមួយរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR) បានរកឃើញថា ជនជាប់ចោទ ឬ ចុងចោទក្នុងបណ្ដឹងបទល្មើសព្រហ្មទណ្ឌមួយចំនួន បានរងការចាប់ឃុំខ្លួន និងកាត់ទោសដោយពុំមានមេធាវី។



RFA/Sok Serey

*ទណ្ឌិតជាស្ត្រីចូលរួមអបអរសាទរទិវានារីអន្តរជាតិលើកទី៩៩ ដែលបានប្រារព្ធធ្វើឡើងនៅក្នុងបរិវេណពន្ធនាគារព្រៃស ក្នុងរាជធានីភ្នំពេញ នៅថ្ងៃទី៨ ខែមីនា ឆ្នាំ២០១០។*

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ដែលបានធ្វើការសិក្សាស្រាវជ្រាវ និងឃ្លាំមើលសវនាការចំនួន ១.៣១៧សវនាការនៅសាលាដំបូងក្រុងភ្នំពេញ និងតុលាការខេត្តកណ្ដាល កន្លងមក បានរកឃើញថា គឺមានសវនាការតែចំនួន ១៩៩ករណីទេ ដែលតុលាការបានបំពេញការងារបានល្អប្រសើរក្នុងការប្រាប់ជនជាប់ចោទឲ្យបានដឹងអំពីបទល្មើស និងបទចោទប្រកាន់។ ប៉ុន្តែក្នុងនោះដែរ គេឃើញចំនួនជនជាប់ចោទរងការឃុំខ្លួនបណ្ដោះអាសន្នមានកម្រិតខ្ពស់ និងខ្វះមេធាវីការពារក្ដី។

ការសិក្សាស្រាវជ្រាវនេះបានចាប់ផ្ដើមពីខែសីហា ឆ្នាំ២០០៩ និងបានចេញរបាយការណ៍ប្រចាំឆមាសទី១ នៅខែកក្កដា ឆ្នាំ២០១០ ហើយត្រូវបានគេចេញផ្សាយនៅសប្ដាហ៍នេះ។

ក្នុងរបាយការណ៍បានបញ្ជាក់ថា មូលហេតុដែលខ្វះមេធាវីនោះ គឺដោយសារជនជាប់ចោទមានជីវភាពក្រីក្រ គ្មានប្រាក់ជួលមេធាវីការពារក្ដី និងកង្វះខាតចំនួនមេធាវីតែម្ដង ហើយម្យ៉ាងទៀត ប្រជាពលរដ្ឋមិនបានយល់ដឹងឡើយអំពីសារសំខាន់របស់មេធាវីការពារក្ដី។

អ្នកស្រាវជ្រាវរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា លោកស្រី ម៉ាង ម៉ូនីកា បានមានប្រសាសន៍ថា ការស្រាវជ្រាវនេះគឺបានផ្ដោតលើតែជនជាប់ចោទ ឬចុងចោទនៃសំណុំរឿងព្រហ្មទណ្ឌតែប៉ុណ្ណោះ រាប់ទាំងអនីតិជន និងមនុស្សពេញវ័យ ដូចជាអំពើប្លន់ និងអំពើមនុស្សឃាតជាដើម ៖ *«អ៊ីចឹងគោលបំណងធំនោះ គឺសំដៅចូលរួមនៅក្នុងការធ្វើកំណែទម្រង់ប្រព័ន្ធយុត្តិធម៌»*។

លោកស្រី ម៉ូនីកា បានឲ្យដឹងថា នៅថ្ងៃខាងមុខ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា នឹងពង្រីកគម្រោងសិក្សាស្រាវជ្រាវបែបនេះនៅតុលាការខេត្តបន្ទាយមានជ័យ និងតុលាការខេត្តរតនគិរី ដើម្បីចាត់ទុកថា ជាតុលាការគំរូ។ តុលាការសាលាដំបូងក្រុងភ្នំពេញ និងតុលាការខេត្តកណ្ដាល ត្រូវបានចាត់ទុកថា ជាតុលាការគំរូក្នុងការសិក្សាស្រាវជ្រាវកន្លងមក។

អគ្គលេខាធិការនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ លោក ស៊ុយ ម៉ុងលាង បានមានប្រសាសន៍នៅក្នុងរបាយការណ៍នោះថា លោកទទួលយក និងគាំទ្រអនុសាសន៍នៅក្នុងរបាយការណ៍ស្រាវជ្រាវនេះ ។

របាយការណ៍ប្រចាំឆ្នាំមុនៗ ពោលគឺនៅមុនឆ្នាំ២០១០ ត្រូវបានមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ដាក់ជូនទៅអង្គការជាដៃគូក្រសួងយុត្តិធម៌ នគរបាលជាតិ មន្ត្រីតុលាការ ព្រមទាំងក្រសួងមហាផ្ទៃ រួចរាល់ហើយ។

ប្រធានប្រតិបត្តិនៃគម្រោងអ្នកការពារក្ដីកម្ពុជា លោក សុក សំអឿន បានមានប្រសាសន៍ថា ប្រជាពលរដ្ឋភាគច្រើនត្រូវបានចាប់ខ្លួនដោយគ្មានមេធាវីជួយការពារក្ដីទេ ៖ *«ក្នុងរយៈពេល ២៤ម៉ោង ក្រោយពីការចាប់ខ្លួនហ្នឹង គឺមិនមាននរណាមានមេធាវីក្នុងរយៈពេល ២៤ម៉ោង ក្រោយពីការចាប់ខ្លួនហ្នឹងទី១ ហើយទី២ទៀត ក្នុងច្បាប់យើង គឺតម្រូវឲ្យតុលាការចាត់តាំងឲ្យជនក្រីក្រហ្នឹង គឺមានតែករណី*